# ស្ត្រី និង កុមារ បានរាប់បញ្ចូលក្នុងបញ្ជីឈ្មោះជនរស់រានមានជីវិត ពីមន្ទីរឃុំឃាំងសម្ងាត់របស់ ឌុច

***ដោយ ឡូរ៉ា ម៉ាកដូណល់***

***ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

*ក្នុងអង្គសវនាការថ្ងៃនេះ បុរសរស់រានមានជីវិតពីវាលពិឃាតបឹងជើងឯកម្នាក់ពិតជាមនុស្សលម្អិតមែន ប៉ុន្តែជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទទួលស្គាល់សក្ខីកម្មរបស់ស្ត្រីរួចរស់មានជីវិតពីកន្លែងកសាងខ្លួនព្រៃស (មន្ទីរស-២៤) និងក្មេងម្នាក់ដែលនៅមានជីវិតពីគុកទួលស្លែង (មន្ទីរស-២១) ។*

## ឌុច ទទួលស្គាល់ក្មេងដែលរស់រានមានជីវិតពីមន្ទីរស-២១ និងសុំការអត់ឱនទោស

ដូចដែលបានរាយការណ៍កាលពីម្សិលមិញនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញប្រវត្តិរូបអ្នកទោសមន្ទីរស-២១ឈ្មោះ មុំ យ៉ូវ ដែលជាម្តាយរបស់ នង ចាន់ផល ក្មេងរស់រានមានជីវិតពីមន្ទីរស-២១ដែលបានឡើងមកធ្វើសក្ខីកម្មកាលពីសប្តាហ៍មុន ។ ក្នុងកិច្ចដំណើរការដំបូងនាព្រឹកនេះ ព្រះរាជអាជ្ញាបានប្រកាសពីឯកសារដែលបានរកឃើញនៅចំពោះមុខចៅក្រមសាលាដំបូងដោយស្នើសុំថា ឯកសារនេះគួរតែដាក់បញ្ចូលក្នុងសំណុំរឿង និងដាក់នៅ“ចំពោះមុខ”អង្គជំនុំជម្រះ ។ មេធាវីការពារក្តីមិនបានជំទាស់ឡើយ ប៉ុន្តែបានបង្ហាញថា ខ្លួនមានបំណងជំទាស់នឹងការដាក់បញ្ចូលឯកសារយឺតបែបនេះចូលក្នុងសំណុំរឿងក្នុងករណីដែលកើតឡើងនាពេលអនាគត ។ ក្នុងការឆ្លើយតប លោកប្រធានចៅក្រម និល ណុន បានទទួលយកឯកសារនេះ និងបានពន្យល់ថា ចៅក្រមនឹងធ្វើការពិចារណាថាតើឯកសារយឺតនេះនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ដោយផ្អែកលើមូលដ្ឋានករណីនីមួយៗដែរឬយ៉ាងណា ។ បើយោងតាមវិធានផ្ទៃក្នុងវិញ គ្មានវិធានណាមួយស្តីពីការដាក់កំហិតលើការទទួលយកឯកសារ យឺតបែបនេះទេ ។

ខុសពីសប្តាហ៍មុនដែល ឌុច មិនបានទទួលស្គាល់សក្ខីកម្មរបស់ នង ចាន់ផល ដោយសារតែមូលហេតុថាគ្មានឯកសារឬរូបថតដែលបញ្ជាក់ថាម្តាយរបស់ នង ចាន់ផល ពិតជាត្រូវបានជាប់ឃុំនៅមន្ទីរស-

២១ ហើយជាធម្មតាក្មេងៗទាំងអស់ក៏ត្រូវបានសម្លាប់ចោលនោះ ថ្ងៃនេះ ឌុច បានក្រោកឈរទទួលស្គាល់ប្រវត្តិរូបរបស់ មុំ យ៉ូវ និងសុំការអត់ឱនទោសពី នង ចាន់ផល ។ ឌុច បានឆ្លើយតបដោយសេចក្តីគោរពយ៉ាងពិតប្រាកដថា តាមរយៈតុលាការ«ខ្ញុំសូមស្នើសុំការអត់ឱនទោសពី នង ចាន់ផល» ។

## តើ ភោគ ខន ពិតជាបានរត់រួចពីវាលពិឃាតបឹងជើងឯកមែនដែរឬទេ?

កាលពីម្សិលមិញនេះ ចៅក្រមបានបញ្ចប់ការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី ភោគ ខន អាយុ៥៧ឆ្នាំដែលអះអាងថា គាត់បានរស់រានមានជីវិតពីមន្ទីរស-២១ និងកន្លែងដែលខ្មែរក្រហមបំណងនឹងសម្លាប់នៅវាលពិឃាតបឹងជើងឯក ។ ថ្ងៃនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងដំណើរនីតិវិធីចាប់ផ្តើមសួរសំណួរ ដើម្បីធ្វើការយល់ដឹងពីរឿងរ៉ាវដ៏គួរឲ្យចាប់អារម្មណ៍របស់ ភោគ ខន ។

ភោគ ខន បានចូលបំរើកងទ័ពខ្មែរក្រហមនៅអាយុ១៥ឆ្នាំ ហើយក្រោយមកទៀតត្រូវបានបង្ខំឲ្យរៀបការជាមួយនឹងនារីម្នាក់ដែលគាត់មិនដែលបានជួបពីមុនមក ។ ភោគ ខន បានជួយជន្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងបានបំរើការងារនៅក្នុងកងជាច្រើនដូចជា កងគេអូ និងកងស្ពាបនាផ្លូវដែក ។ ក្នុងឆ្នាំ១៩៧៨ ភោគ ខន ត្រូវបានចាប់ខ្លួន នឹងបញ្ជូនមកកាន់មន្ទីរឃុំឃាំងដែលគាត់ជឿថា ជាមន្ទីរស-២១ ។ ក្នុងអំឡុងពេលជាប់ឃុំឃាំងបី-បួនខែ គាត់ត្រូវបានសួរចម្លើយ និងទទួលរងការធ្វើទារុណកម្មពីរ-បីដងដែរ ។ គាត់អះអាងថា ឌុច ដែលអ្នកសួរចម្លើយទាំងអស់ហៅថា«បងខាងកើត»ក៏ធ្លាប់មានវត្តមានប្រមាណដប់ប្រាំទៅម្ភៃនាទីនៅក្នុងពេលគាត់ត្រូវបានសួរចម្លើយជាលើកដំបូងដែរ ។ ថ្ងៃមួយ ភោគ ខន និងអ្នកទោសប្រហែលសាមសិបនាក់ទៀត ត្រូវបានបញ្ជូនទៅកាន់កន្លែងមួយដែលគាត់ជឿថាជាវាលពិឃាតបឹងជើងឯក ។ ក្រោយពីបានចំណាយពេលនៅក្នុងផ្ទះឈើមួយរយៈមក គាត់ត្រូវបាននាំចេញមកកាន់រណ្តៅជាមួយនឹងអ្នកទោសប្រាំនាក់ផ្សេងទៀត ។ ភោគ ខន បានរងនូវការវាយនឹងកាំភ្លើងចំដងក និងផ្អើងជំនីមុននឹងធ្លាក់ចូលក្នុងរណ្តៅទាំងមិនដឹងខ្លួន ។ គាត់បានដឹងខ្លួនឡើងវិញ ដោយឃើញសាកសពនៅលើគាត់ ។ ភោគ ខន បានព្យាយាមរត់មកកាន់ស្ទឹងមួយ ហើយបានប្រើឈើបណ្តែតខ្លួនមកកាន់ទីក្រុងភ្នំពេញ រួចក៏បានជួបនឹងកងទ័ពវៀតណាមនិងកម្ពុជា ដែលគាត់ត្រូវបានគេសង្គ្រោះដាក់លើទូក ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានព្យាយាមសួរថា តើ ភោគ ខន ដឹងថាគាត់ជាប់ឃុំនៅមន្ទីរស-២១ និងត្រូវនាំមកសម្លាប់នៅជើងឯកដោយរបៀបណា ។ ក្នុងឆ្នាំ២០០៨ ភោគ ខន បានមកទស្សនាមន្ទីរស-២១ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលមួយ ដើម្បីស្វែងរកប្រវត្តិរូបរបស់ប្រពន្ធនិងបងប្អូនជីដូនមួយរបស់គាត់ដែលបាត់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម ។ គាត់រកឃើញប្រវត្តិរូបបងប្អូនជីដូនមួយគាត់ ប៉ុន្តែរកមិនឃើញប្រវត្តិរូបរបស់ប្រពន្ធគាត់ឡើយ ។ ពេលនោះ ភោគ ខន បានសន្និដ្ឋានថា គាត់ពិតជាជាប់ឃុំនៅមន្ទីរស-២១មែន ។ ដោយសារតែបឹងជើងឯកជាកន្លែងសម្លាប់អ្នកទោសមន្ទីរស-២១ ភោគ ខន ជឿថា គាត់ពិតជាបានរត់ខ្លួនរួចពីបឹងជើងឯកមែន ។ គាត់បាននិយាយថា ៖ “ខ្ញុំសូមសន្មត់ថា កន្លែងដែលខ្ញុំត្រូវគេសម្លាប់ចោលនោះគឺបឹងជើងឯក បើទោះបីជាខ្លួនខ្ញុំមិនដែលបានទៅទីនោះពីមុនមកក៏ដោយ” ។ ទោះបីជា ភោគ ខន រៀបរាប់ពីឈ្មោះអ្នកសួរចម្លើយពីរនាក់ និងអះអាងថា អ្នកសួរចម្លើយនោះបានហៅឈ្មោះបុរសម្នាក់ដែលបានមកតាមដានការសួរចម្លើយថា “បងខាងកើត”ក៏ដោយ ក៏មេធាវីការពារក្ដីអះអាងថា ភោគ ខន បានលើកឡើងពីព័ត៌មាននេះតាមរយៈសក្ខីកម្មរបស់ជនរស់រានមានជីវិតផ្សេងទៀត ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញប្រវត្តិរូបមួយដែលអាចមានប្រភពពីមន្ទីរស-២១ ។ នៅក្នុងប្រវត្តិរូបនោះមានឈ្មោះមួយដែល ភោគ ខន បញ្ជាក់ថាឈ្មោះនេះគាត់ធ្លាប់ស្គាល់ ប៉ុន្តែកាលពីម្សិលមិញ នៅពេលដែលចៅក្រម ឡាវែន៍ សួរថា ឈ្មោះនោះ“មានអ្វីជាប់ពាក់ព័ន្ធនឹងគាត់”ដែរឬទេ ភោគ ខន បានឆ្លើយថា មិនមានជាប់ពាក់ព័ន្ធអ្វីទេ ។ ម្សិលមិញនេះ ភោគ ខន បាននិយាយបន្ថែមទៀតថា បើទោះបីជាគាត់ស្គាល់ឈ្មោះនៅក្នុងប្រវត្តិរូបនោះក៏ដោយ ក៏ព័ត៌មាននៅក្នុងឯកសារនោះមិនមានអ្វីទាក់ទងនឹងគាត់ឡើយ ។ ថ្ងៃនេះ ភោគ ខន នៅតែអះអាងថាប្រវត្តិរូបនេះមិនបានផ្ដល់ព័ត៌មានអ្វីទាក់ទងនឹងគាត់ទេ ទោះបីជាវាជាអតីតឈ្មោះរបស់គាត់ក៏ដោយ ។ ខណៈពេលសង្កត់ធ្ងន់ទៅលើការនិយាយខុសគ្នារបស់គាត់ ភោគ ខន បានពន្យល់ថា ប្រហែលជាគាត់មិនយល់សំណួរកាលពីម្សិលមិញ ។ ឌុច បានទទួលស្គាល់ថា បងប្អូនជីដូនមួយរបស់ ភោគ ខន ពិតជាត្រូវបានឃុំខ្លួន និងកម្ទេចនៅមន្ទីរស-២១មែន ដោយសារតែមានឯកសារបញ្ជាក់ ប៉ុន្តែ ឌុច អះអាងថា មិនបានដឹងថា ភោគ ខន និងប្រពន្ធរបស់គាត់ជាប់ឃុំនៅមន្ទីរស-២១មែនដែរឬទេ ។

ជាថ្មីម្ដងទៀតនៅក្នុងថ្ងៃនេះ ភោគ ខន ត្រូវបានបង្ខំឲ្យពន្យល់ពីមូលហេតុនៃភាពខុសគ្នារវាងការធ្វើសក្ខីកម្មផ្ទាល់មាត់និងឯកសារជាលាយលក្ខអក្សរ ដែលអមមកជាមួយនឹងពាក្យស្នើសុំធ្វើដើមបណ្ដឹងរដ្ឋប្ប

វេណី ។ ភោគ ខន ពន្យល់ថា គាត់ជួបជាមួយនឹងអង្គការអភិវឌ្ឍន៍សិទ្ធិមនុស្សកម្ពុជាដែលជាអង្គការមិនយកប្រយោជន៍ក្នុងអំឡុងពេលមានការជួបជុំពិភាក្សាក្នុងភូមិ ។ ពេលនោះអ្នកតំណាងរបស់អង្គការនេះបានកត់ត្រារឿងរ៉ាវរបស់គាត់ ។ កំណត់ត្រាជាលាយលក្ខអក្សរត្រូវបានបញ្ជូនមកគាត់វិញតាមរយៈអង្គការមួយផ្សេងទៀតដើម្បីផ្ដិតមេដៃ ។ នាពេលនោះ ភោគ ខន បានថតចម្លងឯកសារនោះ ប៉ុន្តែមិនបានអានដោយយកចិត្តទុកដាក់នោះទេ ពីព្រោះអង្គការនោះប្រាប់គាត់ថា គាត់ត្រូវប្រគល់ឯកសារនោះមកវិញជាបន្ទាន់ ។ សក្ខីកម្មដែលសរសេរជាលាយលក្ខអក្សរបានរៀបរាប់ថា ឌុច បានសួរចម្លើយ ភោគ ខន ដោយគម្រាមសម្លាប់គាត់និងប្រពន្ធ ហើយបង្ខំឲ្យ ភោគ ខន ផឹកទឹករហូតទាល់តែគាត់សន្លប់ ។ នៅក្នុងអង្គសវនាការវិញ ភោគ ខន បាននិយាយថា គាត់មិនហ៊ានមើលមុខ ឌុច ដែលអង្គុយនៅលើកៅអី និងពិនិត្យមើលការសួរចម្លើយឡើយ ។ ភោគ ខន បានទទួលស្គាល់ថា សក្ខីកម្មជាលាយលក្ខអក្សរនោះមានកំហុសមែន ហើយសូមទោសដល់អង្គជំនុំជម្រះ ។

## ស្ត្រីម្នាក់បានរួចរស់រានមានជីវិតពីកន្លែងទាសករពលិកម្ម

នាព្រឹកនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ជិន ម៉េត អាយុ៥១ឆ្នាំ ត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួន ។ គាត់ចង់រកយុត្តិធម៌ឲ្យខ្លួនគាត់ និងមិត្តរួមការងារប្រាំនាក់ដែលបំរើកងទ័ពខ្មែរក្រហមជាមួយគ្នាដែលគាត់បានត្រឹមតែស្គាល់ត្រកូលឈ្មោះរបស់អ្នកទាំងនោះប៉ុណ្ណោះ ។

ក្នុងកិច្ចឆ្លើយតបនឹងសំណួររបស់ចៅក្រម ជិន ម៉េត បានផ្ដល់នូវរឿងរ៉ាវដ៏លម្អិតស្ដីពីបទពិសោធន៍ជីវិតរបស់គាត់នៅក្នុងអំឡុងរបបខ្មែរក្រហម ។ គាត់បានបំរើការនៅក្នុងកងទ័ពនារីដោយបំពេញតួនាទីយ៉ាងច្រើនដូចជា ដឹកអាហាររបួសចេញពីសមរភូមិ និងចិញ្ចឹមជ្រូកជាដើម ។ ក្នុងឆ្នាំ១៩៧៧ សមាជិកជាច្រើននៅក្នុងកងរបស់គាត់ចាប់ផ្ដើមបាត់ខ្លួន ហើយថ្នាក់លើគាត់បានសរសេរប្រវត្តិរូបរបស់គាត់ ។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ជិន ម៉េត ត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកកាន់មន្ទីរឃុំឃាំងមួយដែលគាត់ជឿថា ជាមន្ទីរស-២១ ។ គាត់ត្រូវបានជាប់ឃុំឃាំងក្នុងគុកជាមួយនឹងមិត្តនារីពីរនាក់ទៀតដែលបំរើការក្នុងកងជាមួយគ្នា ។ ប៉ុន្មានថ្ងៃក្រោយមក គាត់ត្រូវបានសួរចម្លើយ និងទទួលរងការធ្វើទារុណកម្ម ។ ក្រោយពីដប់ប្រាំយប់ដប់ប្រាំថ្ងៃ ជិន ម៉េត និងមិត្តនារីពីរនាក់ទៀតត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២៤ ហើយបង្ខំឲ្យធ្វើការងារពលិកម្ម ។

ស្ថានភាពនៅមន្ទីរស-២៤ពិតជា«លំបាកវេទនា» ដែលស្ទើរតែបង្ខំឲ្យស្ត្រីទាំងអស់ពិភាក្សាគ្នាថា តើពួកគេគួរតែធ្វើអត្តឃាតឬក៏អត់ ។ អ្នកទោសស្រីទាំងអស់មានសុខភាពទ្រុឌទ្រោម ស្គម និងពោរពេញទៅដោយរមាស់ និងរបួសគ្រប់ប្រភេទទាំងអស់ ។ ពួកគេត្រូវបានដាស់ឲ្យក្រោកនៅម៉ោងពីរកន្លះយប់ដើម្បីទៅធ្វើស្រែ ដោយធ្វើដំណើរក្នុងរយៈពេលជាច្រើនម៉ោងឆ្ងាយពីទីកន្លែងពួកគេស្នាក់នៅ ។ ដោយមានតែអាហារ និងទឹកតិចតួច អ្នកទោសស្រីទាំងអស់ត្រូវតែធ្វើការរហូតដល់សម្រេចតាមកម្រិតការងាររបស់ខ្លួនដូចជាជីកប្រឡាយ ឬច្រូតស្រូវជាដើម ។ អ្នកទោសស្រីត្រូវខ្មែរក្រហមវាយធ្វើបាបប្រសិនបើពួកគេរអ៊ូរទាំ ឬក៏ឈឺ ។ មានអ្នកទោសខ្លះក៏បានស្លាប់នៅមន្ទីរស-២៤ដែរ ប៉ុន្តែជាញឹកញាប់អ្នកទោសភាគច្រើនតែងតែបាត់ខ្លួន ។

ថ្ងៃមួយ ជិន ម៉េត មានសុខភាពខ្សោយណាស់រហូតដល់គាត់មិនបំពេញការងារដែលកម្រិតឲ្យធ្វើនោះបានទេ ។ ក្រោយពីសន្លប់ និងទទួលរងការវាយធ្វើបាបប៉ុន្មានដងមក គាត់ត្រូវបានដោយបុរសពីរនាក់ផ្ទេរទៅកន្លែងផ្សេង ។ នៅទីនោះ គាត់គ្រាន់តែដាំបន្លែ និងទទួលបានស្ថានភាពប្រសើរជាងមុនដោយមានរបបអាហារគ្រប់គ្រាន់ ។ គាត់បាននៅកន្លែងនោះរហូតដល់កងទ័ពវៀតណាមវាយលុកចូលដល់តំបន់រំដោះ ។ នៅពេលនោះហើយដែលអ្នកទោសស្រីទាំងអស់នាំគ្នារត់ភៀសខ្លួន ។ បន្ទាប់ពីលាក់ខ្លួន និងរត់គេចខ្លួនជាច្រើនខែមក ជិន ម៉េត ត្រូវបានស្ត្រីចំណាស់ម្នាក់ទទួលចិញ្ចឹមនៅក្នុងភូមិតូចមួយដែលគាត់បានចាប់ផ្តើមជីវិតសាមញ្ញជាកសិករម្នាក់ ។

ជិន ម៉េត បានឮពីសារមន្ទីរទួលស្លែង ប៉ុន្តែគាត់មិនដែលចង់មកទស្សនាកន្លែងនេះឡើយ ។ យ៉ាងណាមិញ សាច់ញាតិរបស់គាត់ម្នាក់បានមកទស្សនាសារមន្ទីរទួលស្លែង ហើយក៏បានឃើញរូបថតរបស់ ជិន ម៉េត នៅទីនោះ រួចក៏បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ជិន ម៉េត នៅរស់រានមានជីវិតធម្មតាទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទាក់ទង ជិន ម៉េត ដើម្បីតាមដានរឿងរ៉ាវរបស់គាត់ ។

ចៅក្រមបានបង្ហាញរូបថតសខ្មៅរបស់ស្ត្រីម្នាក់នៅលើកញ្ចក់អេក្រង់ ។ ជិន ម៉េត បានបញ្ជាក់ថារូបថតនេះគឺជារូបថតរបស់គាត់កាលពីអាយុ១៩ឆ្នាំ ។ រូបថតនេះក៏មានភ្ជាប់ជាមួយនឹងប្រវត្តិរូបរបស់គាត់ ។ ឌុច បានបញ្ជាក់ថារូបថតនិងឯកសារនេះមានប្រភពចេញពីមន្ទីរស-២៤ ដោយយោងតាមវិធីសាស្ត្រសរសេររបស់អ្នកនៅក្រោមបង្គាប់របស់ ឌុច ។ ដោយសារតែ ជិន ម៉េត មិនអាចបញ្ជាក់ឲ្យប្រាកដថាគាត់ពិតជាបានជាប់ឃុំឃាំងនៅមន្ទីរស-២១មុននឹងបញ្ជូនទៅមន្ទីរស-២៤ លោកប្រធានក៏ស្នើឲ្យ ឌុច

ធ្វើការអធិប្បាយចំពោះបញ្ហានេះ ។ ឌុច បានសន្និដ្ឋានថា ជិន ម៉េត មិនត្រូវបានឃុំឃាំងនៅមន្ទីរស-២១ឡើយ ។ ផ្ទុយទៅវិញ ជិន ម៉េត បានជាប់ឃុំឃាំងនៅមន្ទីរឃុំឃាំងកងពលរបស់គាត់មុននឹងបញ្ជូនមកកាន់មន្ទីរស-២៤ ។ ឌុច បានពន្យល់ថាប្រសិនបើគាត់ពិតជាត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១មែននោះ គាត់ប្រហែលជាត្រូវស្លាប់បាត់ទៅហើយ ។ មនុស្សដែលត្រូវបានបញ្ជូនពីកងពលមកកាន់មន្ទីរស-២១សុទ្ធតែត្រូវកម្ទេចចោលទាំងអស់ ។

សក្ខីកម្មរបស់ ជិន ម៉េត បានបញ្ចប់ទៅយ៉ាងខ្លី ដូច្នេះគាត់ត្រូវតែត្រឡប់មកធ្វើសក្ខីកម្មនៅថ្ងៃស្អែកម្តងទៀត ។

## ចៅក្រមបញ្ឈប់ «ការសម្ដែងអាកប្បកិរិយាមិនមានសណ្ដាប់ធ្នាប់»

មុនពេលឈប់សម្រាកជាលើកដំបូងនាថ្ងៃនេះ លោកប្រធានបានមានប្រសាសន៍ថា ចៅក្រមបានកត់សម្គាល់ឃើញថា អ្នកតាមដានអង្គសវនាការបានដើរចេញចូលនៅក្នុងសាលសវនាការ ស្របពេលដែលដំណើរការនីតិវិធីកំពុងតែប្រព្រឹត្តទៅ ។ លោកប្រធានបានបង្គាប់ឲ្យបុគ្គលិកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ធ្វើការហាមឃាត់កុំឲ្យការសម្ដែងអាកប្បកិរិយាមិនមានសណ្ដាប់ធ្នាប់បែបនេះបន្តកើតមានឡើយទៀត» ហើយស្នើឲ្យបុគ្គលិកជួយធ្វើឲ្យយ៉ាងណាឲ្យអ្វីៗដំណើរការរលូនទៅមុខបានល្អ ។

ចាប់តាំងពីសក្ខីកម្មរបស់អ្នករស់រានមានជីវិតចាប់ផ្តើមដំណើរការកាលពីថ្ងៃច័ន្ទ មុនមក សាលសវនាការពោរពេញទៅដោយមនុស្សប្រមាណ៦០០នាក់ជារៀងរាល់ថ្ងៃ ។ កាលពីសប្តាហ៍មុន មនុស្សចំនួន២០៧៨នាក់បានតាមដានដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រុមកិច្ចការសាធារណៈបាននាំយកអ្នកភូមិពីខេត្តក្បែរៗនេះតាមរថយន្តក្រុងមកកាន់អង្គសវនាការ ។ បើទោះបីជាការចូលរួមរបស់សាធារណៈជនដ៏ច្រើនកុះករ គឺជាទិដ្ឋភាពមួយដ៏ល្អសម្រាប់ដំណើរការនីតិវិធីក៏ដោយ ក៏បញ្ហាសម្ភារៈនៅតែជួបនឹងបញ្ហាមិនគ្រប់គ្រាន់ ។ វាមិនមានភាពងាយស្រួលទេក្នុងការមានតែឧបករណ៍ស៊ើបរកសម្ភារៈគ្រឿងដែក ត្រួតពិនិត្យកាបូប និងត្រួតពិនិត្យមើលអ្នកតាមដានចេញចូលបន្ទប់សវនាការតែក្នុងរយៈពេលដប់ប្រាំនាទីនោះទេ ។ ជាពិសេស បន្ទប់ទឹកតែងតែមានការករស្ទះរង់ចាំជាជួរ ។ ក្នុងអំឡុងសន្និសិទ្ធិការសែតរបស់កិច្ចការសាធារណៈនាថ្ងៃនេះ អ្នកនាំពាក្យបានលើកឡើងពីការបង្គាប់របស់លោកប្រធានចៅក្រមអង្គជំនុំជម្រះសាលាដំបូង ហើយធ្វើការកត់សម្គាល់ថា តុលាការនេះគឺសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបទាំងអស់ ។

ដោយផ្តល់ជាយោបល់ផ្សេងទៀត  កិច្ចការសាធារណៈបានជម្រុញឲ្យអ្នកសារព័ត៌មានទប់ប្រតិកម្មរបស់ខ្លួនចំពោះដើមបណ្តឹងរដ្ឋប្បវេណី  និងសាក្សីដែលបានលើកមកធ្វើសក្ខីកម្មកន្លងមក  ដោយមូលហេតុថាអ្នកទាំងនោះបានរងបញ្ហាតានតឹងផ្លូវចិត្ត  និងខ្វះខាតនូវជំនួយផ្នែកសតិអារម្មណ៍  ដែលប្រទេសកម្ពុជាមិនមានអស់រយៈពេលសាមសិបឆ្នាំកន្លងមកហើយ ។ អ្នកនាំពាក្យបានពន្យល់ថា  អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា  គឺជាតុលាការអន្តរជាតិដំបូងគេបង្អស់ដែលអនុញ្ញាតឲ្យមានការចូលរួមពីសំណាក់ជនរងគ្រោះជាច្រើនជាងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ។  លើសពីនេះ  ចៅក្រមបានធ្វើការសិក្សានិងសម្របសម្រួលខណៈពេលដែលដំណើរការតុលាការកំពុងបន្តទៅមុខ ។  ប្រសិនបើដំណើរការនីតិវិធីប្រព្រឹត្តទៅមុខតាមកាលវិភាគ  នោះមកដល់ថ្ងៃទី២៦  ខែសីហា  ឆ្នាំ២០០៩  សាក្សីចំនួន១៣នាក់  និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់  នឹងបានលើកមកធ្វើសក្ខីកម្មនៅក្នុងអង្គជំនុំជម្រះរបស់  ឌុច  ជាមិនខាន ។